00384683

C20/5/19

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**ឯកសារដើម**
**ORIGINAL DOCUMENT/DOCUMENT ORIGINAL**
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01 / OCT / 2009
ម៉ោង (Time/Heure) : 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.Zuy

សំណុំរឿងព្រហ្មទណ្ឌ លេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក (អ.ប.ជ ១៦)

# កំណត់ហេតុសវនាការជាលាយលក្ខណ៍អក្សរ

នាវេលាម៉ោង៩ព្រឹក ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានបើកសវនាការជាសាធារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សហចៅក្រមស៊ើបអង្កេត ទៅលើជនត្រូវចោទ **អៀង ធីរិទ្ធ** ហៅ "**ភា**" ភេទស្រី កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់ ៥ ក្រុងភ្នំពេញ ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន នៅផ្ទះលេខ ៤៧បេ ផ្លូវលេខ២១ ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា ឪពុកឈ្មោះ ខៀវ អុន (ស្លាប់) ម្តាយឈ្មោះ អ៊ុក ប៊ុន (ស្លាប់) ជាភរិយារបស់ អៀង សារី មានកូន ៤នាក់។ ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត) ដែលជាបទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា៥, ២៩ (ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 01 / OCT / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.Zuy

**សមាសភាពតុលាការ:**

**១. ចៅក្រម ប្រាក់ គីមសាន ប្រធាន**

**២. ចៅក្រម Rowan DOWNING**

**៣. ចៅក្រម ន័យ ថុល**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

00384684



**៤. ចៅក្រម** Katinka LAHUIS

**៥. ចៅក្រម ហួត វុទ្ធី**

អនុលោមតាមវិធាន ៧៧(៧) នៃវិធានផ្ទៃក្នុង ចៅក្រម **ប៉ែន ពេជ្រសាលី** មានវត្តមានជាចៅក្រមបម្រុង។

**សហព្រះរាជអាជ្ញារង : លោក សេង ប៊ុនឃាង**

**លោក** Vincent de WILDE d'ESTMAEL

**ក្រឡាបញ្ជី: លោក ជួន សុខរាសី**

**លោកស្រី** Anne-Marie BURNS

ជនត្រូវចោទមានវត្តមាន ហើយត្រូវបានតំណាងដោយសហមេធាវីជាតិរបស់លោកស្រី លោក **ផាត់ ពៅស៊ាង**។

ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយ លោក **ហុង គីមសួន** លោក **ឡោ ជុនធី** លោក **គង់ ពិសី** លោក **គីម ម៉េងឃី** កញ្ញា **ម៉ុច សុវណ្ណារី** និង លោក David BLACKMAN។

ប្រធានអង្គបុរេជំនុំជម្រះបានបង្ហាញអំពីអត្តសញ្ញាណជនត្រូវចោទ និងអានបទចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ ដូចបានរៀបរាប់ខាងលើ។ ប្រធានអង្គបុរេជំនុំជម្រះ ប្រាប់ជនត្រូវចោទអំពីសិទ្ធិរបស់លោកស្រី ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ២១(១)(ឃ)។

**ចៅក្រម ហួត វុទ្ធី** អានរបាយការណ៍ត្រួតពិនិត្យសំណុំរឿង។

ប្រធានអង្គបុរេជំនុំជម្រះ សួរជនត្រូវចោទថា តើលោកស្រីចង់ឡើងនិយាយដោយខ្លួនឯងទាក់ទិនទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោកស្រី ឬក៏ចង់ឲ្យមេធាវីរបស់លោកស្រីនិយាយជំនួស។ ជនត្រូវចោទប្រកាសថា គាត់សូមផ្ទេរសិទ្ធិរបស់គាត់ឲ្យទៅសហមេធាវីរបស់គាត់។



E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ចាប់ពីម៉ោង ០៩:៣០ ដល់ម៉ោង ១០:០៥ លោក ផាត់ ពៅស៊ាង ដែលជាសហមេធាវីជាតិ បានធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍នោះ។ គាត់ពន្យល់អំពីទឡ្ហីករណ៍របស់គាត់ថា ហេតុអ្វីបានជាដីកាស្តីពីការបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន គួរត្រូវបានបដិសេធចោល។ ចំពោះទឡ្ហីករណ៍ម្យ៉ាងទៀត គាត់ស្នើឱ្យដោះលែងជនត្រូវចោទដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ និងក្នុងគោលបំណងនេះ អនុម័តសេចក្តីសន្និដ្ឋានដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាបន្តថិរវេលាឃុំខ្លួនបណ្តោះអាសន្ន។ គាត់បានស្នើឱ្យមានលក្ខខណ្ឌដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ឬឃុំខ្លួននៅក្នុងផ្ទះ។ គាត់យោងទៅលើលក្ខខណ្ឌដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលបានស្នើឡើងនៅក្នុងឧបសម្ព័ន្ធ គ នៃបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន។

សវនាការត្រូវបានបន្តធ្វើចាប់ពីម៉ោង ១០:០៥ ដល់ម៉ោង ១០:២៦។

ចាប់ពីម៉ោង ១០:២៦ ដល់ម៉ោង ១០:៤៩ លោក សេង ប៊ុន ឃាង ដែលជាសហព្រះរាជអាជ្ញារងជាតិ បានឡើងធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់លោកឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នោះ ដោយបានលើកទឡ្ហីករណ៍របស់លោកថា ហេតុអ្វីបានជាបណ្តឹងឧទ្ធរណ៍នោះគួរត្រូវបានបដិសេធចោល។

ចាប់ពីម៉ោង ១០:៥០ ដល់ម៉ោង ១១:២៥ លោក Vincent de WILDE d'ESTMAEL ដែលជាព្រះរាជអាជ្ញារងអន្តរជាតិ បានឡើងធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់លោក ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នោះ ដោយនិយាយអំពីលក្ខខណ្ឌពីរដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៦៣(៣)។ ឆ្លើយតបទៅនឹងសំណើដែលធ្វើឡើងដោយផ្ទាល់មាត់របស់សហមេធាវីការពារក្តី សុំឱ្យមានការដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ គាត់បានលើកទឡ្ហីករណ៍ថា លក្ខខណ្ឌក្នុងការដោះលែងដោយដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលបានស្នើឡើងដោយសហមេធាវីការពារក្តីនោះ គឺជាលក្ខខណ្ឌដូចគ្នាដែលអង្គបុរេជំនុំជម្រះបានពិចារណារួចហើយថា មិនអាចទទួលយកបានឡើយ។

ចាប់ពីម៉ោង ១១:២៦ ដល់ម៉ោង ១១:៣៦ លោក ផាត់ ពៅស៊ាង បានធ្វើសេចក្ដីសន្និដ្ឋានតបរបស់គាត់ ដែលនៅពេលនោះគាត់បានធ្វើអត្ថាធិប្បាយជាក់លាក់ទៅលើឯកសារជាភស្តុតាងទាក់ទិនទៅនឹងបទចោទប្រឆាំងនឹងកូនក្ដីរបស់គាត់។

នៅវេលាម៉ោង ១១:៣៧ មេធាវីក្រុម Rowan DOWNING បានសួរសំណួរដល់លោក ផាត់ ពៅស៊ាង ទាក់ទិនទៅនឹងបញ្ហានៃការឃុំខ្លួនក្នុងផ្ទះ។ លោក Vincent de WILDE d'ESTMAEL បានធ្វើការឆ្លើយតប។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់ទៅលើបញ្ហាជាក់លាក់នៃការឃុំខ្លួនក្នុងផ្ទះ ដោយពិចារណាឃើញថា សំណើនោះត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ក្នុងអំឡុងសវនាការ។ លោក ហុង គឹមសួន បានបញ្ជាក់ពីការជំទាស់របស់គាត់ទៅនឹងសំណើសុំឱ្យមានការឃុំខ្លួនក្នុងផ្ទះ។

ចាប់ពីម៉ោង ១១:៥៤ ដល់ម៉ោង ១២:០៩ ជនត្រូវចោទឡើងថ្លែង។

សវនាការបានពន្យារ ចាប់ពីម៉ោង ១២:១០ ដល់ម៉ោង ១២:៣១

ចាប់ពីម៉ោង ១២:៣២ ដល់ម៉ោង ១២:៤៦ លោក ផាត់ ពៅស៊ាង បន្តធ្វើសេចក្ដីសន្និដ្ឋានតបរបស់គាត់ ដោយជជែកអំពីភស្តុតាងនៅក្នុងសំណុំរឿងទាក់ទិនទៅនឹងបទចោទប្រឆាំងនឹងកូនក្ដីរបស់គាត់។

នៅវេលាម៉ោង ១២:៤៩ ប្រធានអង្គបុរេជំនុំជម្រះប្រកាសថា កាលបរិច្ឆេទនៃការបញ្ចូនសេចក្ដីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍នោះ នឹងត្រូវប្រកាសពីរថ្ងៃមុន ហើយបានប្រកាសបិទសវនាការ។

ប្រតិចារិកនៃសវនាការ ត្រូវបានដាក់ភ្ជាប់ជាមួយនឹងកំណត់ហេតុសវនាការជាលាយលក្ខណ៍អក្សរនេះ និងជាផ្នែកនៃកំណត់ហេតុនេះ។

០០២/១៩-០៩-២០០៧-អ.វ.ត.ក (អ.ប.ជ ១៦)

ភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន

**ក្រឡាបញ្ជី**

(ក្រឡាបញ្ជីជាតិមិនបាន
ចុះហត្ថលេខា)

ជួន សុខរាសី

**Anne Marie BURNS**